# របៀបសរសេរសាលក្រម

ថ្ងៃទី18 ខែកញ្ញា ឆ្នាំ 2018

ជំនាញការJICA
Maeda Yuta

# គោលបំណងនៃការធ្វើលិខិតសាលក្រម

① ជាការជូនដំណឹងអំពីខ្លឹមសារនៃសាលក្រម និង ផ្តល់ឱកាសឲ្យភាគីនៃបណ្តឹងពិចារណាថា តើប្តឹងឧបាស្រ័យដែរ ឬ ទេ?

② ជាការបញ្ជាក់ឲ្យកាន់តែច្បាស់ ដើម្បីតុលាការជាន់ខ្ពស់ធ្វើការត្រួតពិនិត្យសាជាថ្មីថា តើតុលាការបានចេញសាលក្រមដោយផ្អែកតាមអង្គហេតុណាមួយ និង មូលហេតុណាមួយដែរឬទេ?

# គោលបំណងនៃការធ្វើលិខិតសាលក្រម

③ ជាការបញ្ជាក់ឲ្យកាន់តែច្បាស់លាស់អំពីខ្លឹមសារច្បាប់ផ្អែកតាមរឿងក្ដីជាក់ស្ដែង និងជាការធានានូវភាពយុត្តិធម៌នៃការសម្រេចសេចក្ដីដោយធ្វើការលើកឡើងអំពីការវិនិច្ឆ័យ និង ដំណាក់កាលនៃការវិនិច្ឆ័យរបស់តុលាការទៅកាន់ប្រជាជនទូទៅ

④ ជាការផ្ដល់ឱកាសឲ្យទៅចៅក្រមដែលនឹងធ្វើការវិនិច្ឆ័យ អាចពិចារណាម្ដងទៀតដោយខ្លួនឯងថា តើនៅមានចំណុចដែលខ្វះខាតចំពោះអង្គហេតុដែលភាគីបានអះអាងដែរឬទេ? មានចំណុចវិវាទត្រង់ចំណុចណាដែរ? មានភស្តុតាងទាក់ទងនឹងចំណុចវិវាទគ្រប់គ្រាន់ហើយឬ នៅជាអាទិ៍?

# ចំណុចដែលត្រូវសរសេរក្នុងលិខិតសាលក្រម

1. សញ្ញាណនៃរឿងក្ដី
2. ចំណងជើង
3. តុលាការ( ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា189 កថាខណ្ឌទី1 ចំណុច ក )
4. ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 189 កថាខណ្ឌទី1 ចំណុច ខ )
5. អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច គ )
6. អង្គហេតុ និង ចំណុចវិវាទ ( ក្រមនីតិវិធីរដ្ឋប្បវេណី189 កថាខណ្ឌទី1 ចំណុច ឃ )
7. សំអាងហេតុ ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី ចំណុច ង )
8. សេចក្ដីសម្រេចបញ្ចប់ ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច ច )
9. ហត្ថលេខាចៅក្រម ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី3 )

# ចំណុចដែលត្រូវសរសេរក្នុង លិខិតសាលក្រម

1. សញ្ញាណនៃរឿងក្តី
2. ចំណងជើង
3. តុលាការ( ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា189 កថាខណ្ឌទី1 ចំណុច ក )
4. ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 189 កថាខណ្ឌទី1 ចំណុច ខ )
5. អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច គ )
6. អង្គហេតុ និង ចំណុចវិវាទ (ក្រមនីតិវិធីរដ្ឋប្បវេណី189 កថាខណ្ឌទី1 ចំណុច ឃ )
7. សំអាងហេតុ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី ចំណុច ង )
8. សេចក្តីសម្រេចបញ្ចប់ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច ច )
9. ហត្ថលេខាចៅក្រម (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី3 )

# សញ្ញាណនៃរឿងក្ដី

ត្រូវសរសេរអំពីលេខសំណុំរឿង ដើម្បីបញ្ជាក់ឲ្យច្បាស់ថាតើជាសាលក្រមទាក់ទងនឹងសំណុំរឿងណាមួយ។

ឧទាហរណ៍៖ សំណុំរឿងរដ្ឋប្បវេណីលេខ 819 ចុះថ្ងៃទី1 ខែវិច្ឆិកា ឆ្នាំ2014

# ចំណុចដែលត្រូវសរសេរក្នុងលិខិតសាលក្រម

1. សញ្ញាណនៃរឿងក្ដី
2. **ចំណងជើង**
3. តុលាការ( ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា189 កថាខណ្ឌទី1 ចំណុច ក )
4. ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 189 កថាខណ្ឌទី1 ចំណុច ខ )
5. អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច គ )
6. អង្គហេតុ និង ចំណុចវិវាទ (ក្រមនីតិវិធីរដ្ឋប្បវេណី189 កថាខណ្ឌទី1 ចំណុច ឃ )
7. សំអាងហេតុ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី ចំណុច ង )
8. សេចក្ដីសម្រេចបញ្ចប់ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច ច )
9. ហត្ថលេខាចៅក្រម (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី3 )

# ចំណងជើង

ត្រូវដាក់ចំណងជើងឲ្យសមស្របទៅនឹងប្រភេទនៃសាលក្រម ដើម្បីបង្ហាញអំពីខ្លឹមសារឲ្យបានច្បាស់លាស់ដោយគ្រាន់តែមើលមួយភ្លែត។ យ៉ាងណាមិញ ចំពោះសាលក្រមនៃរឿងក្ដីដែលមានចំនួនទឹកប្រាក់តិច ត្រូវដាក់ថា "សាលក្រមនៃរឿងក្ដីដែលមានចំនួនទឹកប្រាក់តិច"(ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា236 កថាខណ្ឌទី4)។

ឧទាហរណ៍នៃការសរសេរ៖

"សាលក្រម" (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា180)
"សាលក្រមរបៀប" (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា181)
"សាលក្រមបន្ថែម"(ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា183)

# ចំណងជើង

ម្យ៉ាងវិញទៀត នៅប្រទេសកម្ពុជា យោងតាមរដ្ឋធម្មនុញ្ញមាត្រា129 (ថ្មី) ការជម្រះក្តីធ្វើឡើងក្នុងនាមប្រជារាស្ត្រខ្មែរ ដូចនេះគួរតែសរសេរពាក្យពេចន៍ដែលបង្ហាញការតំណាងនោះបន្តពីចំណងជើង។

ឧទាហរណ៍ ៖ ‶ក្នុងនាមជាប្រជារាស្ត្រខ្មែរ″

# ចំណុចដែលត្រូវសរសេរក្នុងលិខិតសាលក្រម

1. សញ្ញាណនៃរឿងក្តី
2. ចំណងជើង
3. តុលាការ( ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨៩ កថាខណ្ឌទី1 ចំណុច ក )
4. ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ១៨៩ កថាខណ្ឌទី1 ចំណុច ខ )
5. អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា១៨៩ កថាខណ្ឌទី1 ចំណុច គ )
6. អង្គហេតុ និង ចំណុចវិវាទ ( ក្រមនីតិវិធីរដ្ឋប្បវេណី១៨៩ កថាខណ្ឌទី1 ចំណុច ឃ )
7. សំអាងហេតុ ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា១៨៩ កថាខណ្ឌទី ចំណុច ង )
8. សេចក្តីសម្រេចបញ្ចប់ ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា១៨៩ កថាខណ្ឌទី1 ចំណុច ច )
9. ហត្ថលេខាចៅក្រម ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា១៨៩ កថាខណ្ឌទី3 )

# តុលាការ

ចាំបាច់ត្រូវតែសរសេរ ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់អំពីតុលាការដែលបានចេញសាលក្រម (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច ក)។

# ចំណុចដែលត្រូវសរសេរក្នុងលិខិតសាលក្រម

1. សញ្ញាណនៃរឿងក្តី
2. ចំណងជើង
3. តុលាការ( ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៨៩ កថាខណ្ឌទី1 ចំណុច ក )
4. **ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ១៨៩ កថាខណ្ឌទី1 ចំណុច ខ )**
5. អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា១៨៩ កថាខណ្ឌទី1 ចំណុច គ )
6. អង្គហេតុ និង ចំណុចវិវាទ (ក្រមនីតិវិធីរដ្ឋប្បវេណី១៨៩ កថាខណ្ឌទី1 ចំណុច ឃ )
7. សំអាងហេតុ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា១៨៩ កថាខណ្ឌទី ចំណុច ង )
8. សេចក្តីសម្រេចបញ្ចប់ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា១៨៩ កថាខណ្ឌទី1 ចំណុច ច )
9. ហត្ថលេខាចៅក្រម (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា១៨៩ កថាខណ្ឌទី3 )

# ថ្ងៃដែលបានបញ្ចប់ការទាញហេតុផល ដោយផ្ទាល់មាត់

នៅពេលដែលសាលក្រមចូលជាស្ថាពរ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នឹងត្រូវកំណត់ជាស្ថាពរ ផ្អែកតាមអានុភាពនៃអាជ្ញាអស់ជំនុំនោះ (ក្រមនីតិវិធីដ្ឋប្បវេណីមាត្រា194)។ ដើម្បីបញ្ជាក់អំពីពេលវេលាដែលជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំនេះឲ្យកាន់តែច្បាស់លាស់ ត្រូវសរសេរអំពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច ខ)។

# ចំណុចដែលត្រូវសរសេរក្នុងលិខិតសាលក្រម

1. សញ្ញាណនៃរឿងក្ដី
2. ចំណងជើង
3. តុលាការ( ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា189 កថាខណ្ឌទី1 ចំណុច ក )
4. ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 189 កថាខណ្ឌទី1 ចំណុច ខ )
5. **អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច គ )**
6. អង្គហេតុ និង ចំណុចវិវាទ ( ក្រមនីតិវិធីរដ្ឋប្បវេណី189 កថាខណ្ឌទី1 ចំណុច ឃ )
7. សំអាងហេតុ ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី ចំណុច ង )
8. សេចក្ដីសម្រេចបញ្ចប់ ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច ច )
9. ហត្ថលេខាចៅក្រម ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី3 )

# អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍

- ចំណុចដែលត្រូវបានទាមទារឲ្យសរសេរផ្អែកតាមច្បាប់ គឺ "ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់" (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា១៨៩ កថាខណ្ឌទី1 ចំណុច គ)។ យ៉ាងណាមិញ ចំពោះបញ្ញត្តិអំពីអ្នកតំណាងដែលច្បាប់បានកំណត់ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវអនុវត្តដូចគ្នាចំពោះអ្នកតំណាងនៃនីតិបុគ្គល (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៣៨) ដូចនេះ បើសិនភាគីជានីតិបុគ្គល ចាំបាច់ត្រូវសរសេរឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាង។

- ការទាមទារឲ្យសរសេរដូចបានលើកឡើងខាងលើ គឺដើម្បីកំណត់អំពីភាគីឲ្យបានច្បាស់លាស់។ នៅប្រទេសជប៉ុន គេធ្វើការកំណត់ភាគីតាមរយៈអាសយដ្ឋាន និង ឈ្មោះ (នាមករណ៍)។ បើសិនជានៅប្រទេសកម្ពុជាចាំបាច់ត្រូវការពត៌មានច្រើនដើម្បីកំណត់ភាគី ដូច្នេះ គួរតែសរសេរអំពីពត៌មានទាំងនោះ (ថ្ងៃខែឆ្នាំកំណើត ឬ លេខអត្តសញ្ញាណប័ណ្ណ ជាអាទិ៍)។

# អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍

1. ភាគី

- ដោយសារតែអ្នកចូលរួមធ្វើសហបណ្តឹង គឺជាភាគី (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 49) ហេតុនេះ ចាំបាច់ត្រូវតែសរសេរអំពីអ្នកចូលរួមធ្វើសហបណ្តឹងនោះ។ បុគ្គលដែលពាក់ព័ន្ធនឹងនីតិវិធី ហើយទទួលរងអានុភាពនៃសាលក្រមក៏ត្រូវសរសេរចូលផងដែរដូចជា អ្នកចូលរួមជួយអន្តរាគមន៍ ជាដើម។

- នៅពេលសរសេរអំពីភាគី ចាំបាច់ត្រូវតែសរសេរឲ្យត្រូវនឹងឋានៈរបស់ភាគី ដូចជា "ដើមចោទ" ឬ "ចុងបណ្តឹងឧទ្ធរណ៍" ជាអាទិ៍។ នៅប្រទេសជប៉ុន គេសរសេរអំពីដើមចោទមុន ហើយចុងចម្លើយជាក្រោយ រីឯតុលាការនៃបណ្តឹងឧទ្ធរណ៍ គេសរសេរដើមបណ្តឹងឧទ្ធរណ៍មុន និងចុងបណ្តឹងឧទ្ធរណ៍ជាក្រោយ ទោះបីជានៅក្នុងការជំនុំជម្រះលើកទី១ ភាគីណាជាដើមចោទក៏ដោយ។

- ចំពោះអាសយដ្ឋានក្រុមហ៊ុន ត្រូវសរសេរអំពីទីតាំងនៃទីស្នាក់ការកណ្តាលដែលមានក្នុងសៀវភៅចុះបញ្ជី។

# អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍

2. អ្នកតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងនៃនីតិបុគ្គល

- អំពីអ្នកតំណាងដែលច្បាប់បានកំណត់ គួរសរសេរអំពីគោលបំណង និង លក្ខណៈសម្បត្តិដែលនឹងក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់។

  ឧទាហរណ៍នៃការសរសេរ ៖ អ្នកមានអំណាចមេបា A ជាអ្នកតំណាងដែលច្បាប់បានកំណត់របស់ដើមចោទ

- អំពីអ្នកតំណាងនៃនីតិបុគ្គល គួរសរសេរអំពីគោលបំណង និង លក្ខណៈសម្បត្តិនៃការតំណាងនោះ។

  ឧទាហរណ៍នៃការសរសេរ ៖ នាយកប្រតិបត្តិ B ជាអ្នកតំណាងរបស់ដើមចោទ

# អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍

3. អ្នកតំណាងដោយអាណត្តិ

- ការសរសេរអំពីអ្នកតំណាងដោយអាណត្តិ មិនមែនជាចំណុចដែលទាមទារឲ្យសរសេរផ្អែកតាមច្បាប់ទេ ប៉ុន្តែ ត្រូវតែសរសេរ ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់អំពីជនដែលធ្វើបណ្តឹងជាក់ស្តែង និងដើម្បីងាយស្រួលធ្វើការបញ្ជូន។

- នៅពេលដែលអ្នកតំណាងដោយអាណត្តិគឺជាមេធាវី នោះនឹងត្រូវបានផ្តល់ឲ្យនូវឋានៈពិសេសផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 53 កថាខណ្ឌទី1) ហើយដើម្បីបង្ហាញអំពីចំណុចនេះ ត្រូវសរសេរយ៉ាងណាដើម្បីឲ្យយល់ថាជាមេធាវី។
ឧទាហរណ៍៖ មេធាវីជាអ្នកតំណាងដោយអាណត្តិរបស់ដើមចោទA

# ចំណុចដែលត្រូវសរសេរក្នុងលិខិតសាលក្រម

1. សញ្ញាណនៃរឿងក្តី
2. ចំណងជើង
3. តុលាការ(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា189 កថាខណ្ឌទី1 ចំណុច ក)
4. ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់(ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 189 កថាខណ្ឌទី1 ចំណុច ខ)
5. អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍(ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច គ)
6. **អង្គហេតុ និង ចំណុចវិវាទ (ក្រមនីតិវិធីរដ្ឋប្បវេណី189 កថាខណ្ឌទី1 ចំណុច ឃ)**
7. សំអាងហេតុ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី ចំណុច ង)
8. សេចក្តីសម្រេចបញ្ចប់ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច ច)
9. ហត្ថលេខាចៅក្រម (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី3)

# អង្គហេតុ និង ចំណុចវិវាទ

- ចំពោះការសរសេរអំពី អង្គហេតុ និង ចំណុចវិវាទ ត្រូវសរសេរខ្លឹមសារសំខាន់ៗដោយផ្អែកលើសេចក្តីថ្លែងការណ៍របស់ភាគី (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី2)។

⇒មូលដ្ឋានដែលត្រូវយកមកសរសេរអំពី អង្គហេតុ និង ចំណុចវិវាទ គឺជាសេចក្តីថ្លែងការណ៍របស់ភាគី។

- ចុះបើសេចក្តីថ្លែងការណ៍របស់ភាគីមានខ្លឹមសារមិនច្បាស់លាស់ ឬ ផ្ទុយគ្នា តើត្រូវធ្វើដូចម្តេច?

⇒តុលាការត្រូវឲ្យបញ្ជាក់អំពីការអះអាងដោយប្រើសិទ្ធិឲ្យបំភ្លឺឲ្យបានត្រឹមត្រូវ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា90)។

# អង្គហេតុ និង ចំណុចវិវាទ

ចំណុចដែលត្រូវសរសេរអំពីអង្គហេតុ និង ចំណុចវិវាទ នៅក្នុងលិខិតសាលក្រមមានដូចខាងក្រោម៖

A. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

B. ដំណើរនៃរឿងក្តី និង ចំណុចវិវាទ

B. 1 ការសង្ខេបអំពីរឿងក្តី

B. 2 អង្គហេតុដែលគ្មានវិវាទ

B. 3 ចំណុចវិវាទ

B. 4 ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ

# អង្គហេតុ និង ចំណុចវិវាទ

## ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

- ចំពោះខ្លឹមសារនៃសាលក្រមដែលទាមទារឲ្យតុលាការចេញ ជាចំណុចដែលត្រូវសរសេរនៅក្នុងពាក្យបណ្តឹងជាចាំបាច់ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 75 កថាខណ្ឌទី 2 ចំណុច ខ) ដូច្នេះហើយជាមូលដ្ឋានគ្រាន់តែដកស្រង់តាមការសរសេរក្នុងពាក្យបណ្តឹងគឺជាការគ្រប់គ្រាន់។

- ប៉ុន្តែ ក្នុងករណីដែលការសរសេរក្នុងពាក្យបណ្តឹងមានភាពមិនត្រឹមត្រូវដូចជាមានខ្លឹមសារមិនច្បាស់លាស់ ឬ មិនស្របគ្នាជាមួយមូលហេតុនៃការទាមទារ តុលាការត្រូវឲ្យកែតម្រូវនូវខ្លឹមសារឲ្យបានត្រឹមត្រូវផ្អែកតាមការឲ្យបំភ្លឺនៅពេលធ្វើការជំនុំជម្រះ។

# អង្គហេតុ និង ចំណុចវិវាទ
## ដំណើរនៃរឿងក្តី និង ចំណុចវិវាទ

របៀបកំណត់ចំណុចវិវាទ

នៅក្នុងការសម្រេចសេចក្តីនៃរឿងក្តីរដ្ឋប្បវេណី ប្រសិនបើតុលាការទទួលស្គាល់អំពីអានុភាពគតិយុត្តដោយផ្អែកតាមការទទួលស្គាល់អត្ថិភាពនៃអង្គហេតុចម្បង ដូច្នេះ តុលាការនឹងត្រូវវិនិច្ឆ័យដោយផ្អែកលើភស្តុតាងថាតើត្រូវទទួលស្គាល់អង្គហេតុចម្បងដែលភាគីអះអាងដែរ ឬទេ? ហេតុនេះ ជាមូលដ្ឋាននៅក្នុងចំណោមអង្គហេតុ ផ្នែកដែលភាគីម្ខាងទៀត ឬ ភាគីបានបដិសេធ (ឬ មិនដឹង) នឹងក្លាយជាចំណុចវិវាទ។

ប៉ុន្តែ ប្រសិនបើតុលាការត្រូវវាយតម្លៃ អំពី "កំហុស" វិញ តើតុលាការនឹងត្រូវទទួលស្គាល់អំពី កំហុស ដោយផ្អែកតាមកំណត់អំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុដែលភាគីអះអាងដែរទេ? ដូច្នេះហើយជាធម្មតា អង្គហេតុដែលនាំឲ្យតុលាការអាចវាយតម្លៃ ឬ មិនអាចវាយតម្លៃនោះហើយ (ពោលគឺអត្ថិភាព ឬ នត្ថិភាពនៃកំហុស) នឹងត្រូវក្លាយជាចំណុចវិវាទ។

# អង្គហេតុ និង ចំណុចវិវាទ

## ដំណើររឿងក្ដី និង ចំណុចវិវាទ

របៀបកំណត់ចំណុចវិវាទ

នៅក្នុងរឿងក្ដីនេះ តើអ្វីជាចំណុចវិវាទ？



ដើមចោទ

នៅថ្ងៃទី1 ខែកក្កដា ឆ្នាំ2018 ខ្ញុំបានលក់ត្បូង 1 គ្រាប់ ក្នុងតម្លៃ 1 ម៉ឺនដុល្លារទៅឲ្យចុងចម្លើយ ហើយនៅថ្ងៃនោះខ្ញុំបានប្រគល់ទំនិញរួចហើយ ប៉ុន្តែចុងចម្លើយមិនបានបង់ប្រាក់ឲ្យខ្ញុំទេ។ ហេតុនេះ ខ្ញុំទាមទារឲ្យចុងចម្លើយបង់ប្រាក់ចំនួន 1 ម៉ឺនដុល្លារ។

ខ្ញុំបានទទួលការប្រគល់ត្បូង 1 គ្រាប់ពីដើមចោទ ពិតមែន ប៉ុន្តែ វាមិនមែនជារបស់ដែលទិញទេ តែជារបស់ដែលដើមចោទឲ្យខ្ញុំ។



ចុងចម្លើយ

# អង្គហេតុ និង ចំណុចវិវាទ
## ដំណើរនៃរឿងក្តី និង ចំណុចវិវាទ

របៀបកំណត់ចំណុចវិវាទ
ប្លុកដ្យាក្រាមនៃរឿងក្តីនេះ
មូលហេតុនៃការទាមទារ

| | | |
|---|---|---|
| ក | នៅថ្ងៃទី1 ខែកក្កដា ឆ្នាំ2018 ដើមចោទបានលក់ត្បូង 1គ្រាប់ ក្នុងតម្លៃ 1ម៉ឺន ដុល្លារទៅឲ្យចុងចម្លើយ | × |

⇒មាន ឬ គ្មានកិច្ចសន្យាលក់ទិញ នឹងក្លាយជាចំណុចវិវាទ។

# អង្គហេតុ និង ចំណុចវិវាទ

## ដំណើររឿងក្ដី និង ចំណុចវិវាទ

របៀបកំណត់ចំណុចវិវាទ

នៅក្នុងរឿងក្ដីនេះ តើអ្វីជាចំណុចវិវាទ？



ដើមចោទ

នៅថ្ងៃទី1 ខែកក្កដា ឆ្នាំ2018 ខ្ញុំបាន
លក់ត្បូង 1គ្រាប់ ក្នុងតម្លៃ 1ម៉ឺនដុល្លារឲ្យ
ទៅចុងចម្លើយ ហើយនៅថ្ងៃនោះខ្ញុំបាន
ប្រគល់ទំនិញរួចហើយ ប៉ុន្តែចុងចម្លើយ
មិនបានបង់ប្រាក់ឲ្យខ្ញុំទេ។ ហេតុនេះ ខ្ញុំ
ទាមទារឲ្យចុងចម្លើយបង់ប្រាក់ចំនួន
1ម៉ឺនដុល្លារ។

ខ្ញុំបានទិញត្បូងពីដើមចោទ និង
បានទទួលការប្រគល់នោះដូច
ពាក្យដែលដើមចោទបានលើក
ឡើងមែន ប៉ុន្តែ ចំពោះប្រាក់1ម៉ឺន
ដុល្លារខ្ញុំបានបង់នៅពេលប្រគល់
ត្បូងនោះហើយ។



ចុងចម្លើយ

# អង្គហេតុ និង ចំណុចវិវាទ
## ដំណើរនៃរឿងក្តី និង ចំណុចវិវាទ

របៀបកំណត់ចំណុចវិវាទ
ប្លុកដ្យាក្រាមនៃរឿងក្តីនេះ
មូលហេតុនៃការទាមទារ

| ក | នៅថ្ងៃទី1 ខែកក្កដា ឆ្នាំ2018 ដើមចោទបានលក់ត្បូងក្នុងតម្លៃ 1ម៉ឺនដុល្លារឲ្យទៅចុងចម្លើយ។ | ○ |
|---|---|---|

← ការតវ៉ា

| ខ | នៅថ្ងៃទី1 ខែកក្កដា ឆ្នាំ2018 ចុងចម្លើយបានបង់កាតព្វកិច្ចជាប្រាក់1ម៉ឺនដុល្លារនៃ "ក" ទៅឲ្យដើមចោទរួចហើយ។ | × |
|---|---|---|

⇒ការមាន ឬ គ្មានកិច្ចសន្យាលក់ទិញនឹងមិនក្លាយជាចំណុចវិវាទទេ ប៉ុន្តែការមាន ឬ គ្មានការសងទើបក្លាយជាចំណុចវិវាទ។

# អង្គហេតុ និង ចំណុចវិវាទ

## ការសង្ខេបអំពីរឿងក្តី

ជាការបង្ហាញអំពីខ្លឹមសារនៃរឿងក្តីត្រួសៗ។ ចំណុចសំខាន់ត្រង់នេះ គឺជាការបង្ហាញឲ្យច្បាស់អំពីកម្មវត្ថុនៃបណ្តឹង។ ចំណុចនេះ មិនមែនមានន័យថា ជាការសរសេរឡើងវិញទាំងស្រុងអំពីការអះអាងរបស់ដើមចោទទេ។

ឧទាហរណ៍នៃការសរសេរ 1 ៖ ក្នុងរឿងក្តីនេះ គឺជារឿងក្តីដែលដើមចោទទាមទារឲ្យចុងចម្លើយបង់ប្រាក់ថ្លៃលក់ទិញផ្អែកតាមកិច្ចសន្យាលក់ទិញ។

ឧទាហរណ៍នៃការសរសេរ 2 ៖ ក្នុងរឿងក្តីនេះ ដើមចោទបានចុះកិច្ចសន្យាលក់ទិញត្បូងជាមួយនឹងចុងចម្លើយនៅថ្ងៃទី...ខែ.... ឆ្នាំ...... អះអាងថា ចុងចម្លើយមិនបានបង់ប្រាក់ថ្លៃលក់ទិញ ហើយទាមទារទៅកាន់ចុងចម្លើយឲ្យបង់ប្រាក់ថ្លៃលក់ទិញផ្អែកតាមកិច្ចសន្យាលក់ទិញដែលបានសរសេរខាងលើ។

# អង្គហេតុ និង ចំណុចវិវាទ

## អង្គហេតុដែលគ្មានវិវាទ

- នៅក្នុងអង្គហេតុចម្បង និង អង្គហេតុប្រយោលសំខាន់ៗ ត្រូវសរសេរនូវអង្គហេតុដែលភាគីគ្មានវិវាទ។

ឧទាហរណ៍៖ នៅក្នុងរឿងក្ដីទី2 កិច្ចសន្យាលក់ទិញ ឬ ការប្រគល់ត្បូង

- គេគិតថា អង្គហេតុដែលត្រូវបានទទួលស្គាល់ជាក់លាក់ពីភាគីថា ពិតជាគ្មានវិវាទ ឬ អង្គហេតុដែលត្រូវបានទទួលស្គាល់តាមរយៈភស្តុតាង ក៏អាចយកមកសរសេរនៅត្រង់ចំណុចនេះបានដែរ ដោយដាក់ចំណងជើងថា "អង្គហេតុដែលគ្មានវិវាទ និង អង្គហេតុដែលត្រូវបានទទួលស្គាល់ជាក់លាក់តាមរយៈភស្តុតាង" (ប៉ុន្តែ មិនគួរធ្វើបែបនេះទេ។)។ ក្នុងករណីនេះ ក៏ត្រូវសរសេរនូវភស្តុតាងជាមូលដ្ឋានផងដែរ។

ឧទាហរណ៍៖ ក្នុងករណីដែលកិច្ចសន្យាបានបង្កើត ឬ ក៏អត់ គឺជាចំណុចវិវាទ ចំណុចដែលត្រូវសរសេរគឺ ខ្លឹមសារនៃកិច្ចសន្យា (មាន ឬ គ្មានហត្ថលេខារបស់ចុងចម្លើយ ជាអាទិ៍)

# អង្គហេតុ និង ចំណុចវិវាទ
## ចំណុចវិវាទ

- សរសេរអំពីចំណុចវិវាទដែលបានកំណត់ដាក់លាក់ដែលបានពីលទ្ធផលនៃការជំនុំជម្រះ

ឧទាហរណ៍នៃការសរសេរ ៖ តើដើមចោទបានបង់ប្រាក់ថ្លៃលក់ទិញរថយន្តឲ្យទៅចុងចម្លើយទេ?

- ក្នុងករណីដែលចុងចម្លើយមិនមានវិវាទអំពីមូលហេតុនៃការទាមទារដែលដើមចោទអះអាង និង មិនដាក់នូវការតវ៉ាណាមួយទេ  នោះតុលាការមានតែត្រូវសរសេរថា "ដោយសារតែចុងចម្លើយទទួលស្គាល់ការអះអាងគ្រប់ចំណុចរបស់ដើមចោទ ដូចនេះមិនមានចំណុចវិវាទទេ។" ជាអាទិ៍តែប៉ុណ្ណោះ។ ឬក៏អាចកាត់ចោលនូវចំណុចដែលស្តីពី ចំណុចវិវាទ បើសិនជានៅអាចអានក្នុងលិខិតសាលក្រមទាំងមូល ហើយដឹងអំពីចំណុច គ្មានចំណុចវិវាទ។

# អង្គហេតុ និង ចំណុចវិវាទ
## ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ

- ត្រូវសរសេរអំពីការអះអាងរបស់ភាគីដែលទាក់ទងនឹងចំនុចវិវាទ(អង្គហេតុចម្បង និង អង្គហេតុប្រយោលសំខាន់ៗ) ត្រង់ចំណុចវិវាទនីមួយៗ ។ ជាពិសេស ត្រូវសរសេរទាំងអស់អំពីការអះអាងរបស់ភាគីទាក់ទងនឹងអង្គហេតុចម្បងឲ្យស្របនឹងចំណុចស្តីពី "អង្គហេតុដែលគ្មានវិវាទ"។
- នៅប្រទេសជប៉ុន ជាធម្មតា គេសរសេរអំពីការអះអាងនីមួយៗដោយគោរពតាមលំដាប់ដូចតទៅ "ភាគីដែលមានបន្ទុកត្រូវអះអាងនិង បញ្ជាក់ភស្តុតាងអំពីវិវាទនោះ" → "ភាគីដែលគ្មានបន្ទុកក្នុងការអះអាងនិង បញ្ជាក់ភស្តុតាង" ។

# ចំណុចដែលត្រូវសរសេរក្នុងលិខិតសាលក្រម

1. សញ្ញាណនៃរឿងក្ដី
2. ចំណងជើង
3. តុលាការ(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា189 កថាខណ្ឌទី1 ចំណុច ក)
4. ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់(ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 189 កថាខណ្ឌទី1 ចំណុច ខ)
5. អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍(ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច គ)
6. អង្គហេតុ និង ចំណុចវិវាទ (ក្រមនីតិវិធីរដ្ឋប្បវេណី189 កថាខណ្ឌទី1 ចំណុច ឃ)
7. **សំអាងហេតុ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី ចំណុច ង)**
8. សេចក្ដីសម្រេចបញ្ចប់ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច ច)
9. ហត្ថលេខាចៅក្រម (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី3)

# សំអាងហេតុ

- ការវិនិច្ឆ័យអំពីចំណុចវិវាទ ត្រូវបង្ហាញអំពីទំនាក់ទំនងរវាងអង្គហេតុដែលបានទទួលស្គាល់ និង ភស្តុតាងជាក់លាក់ដែលទាក់ទងនឹងអង្គហេតុនេះតាមដែលអាចធ្វើទៅបាន ហើយត្រូវសរសេរឲ្យមានលក្ខណៈក្បោះក្បាយ។
- ផ្នែកដែលលើកឡើង "តើតុលាការបានទទួលស្គាល់អង្គហេតុមួយណា ពីភស្តុតាងមួយណា?" និង ផ្នែកដែលលើកឡើងថា " តើតុលាការបានវិនិច្ឆ័យយ៉ាងដូចម្តេចផ្អែកតាមអង្គហេតុដែលបានទទួលស្គាល់?" គួរតែសរសេរឲ្យបានច្បាស់លាស់ និងញែកឲ្យដាច់ពីគ្នា។
- ក្នុងករណីដែលតុលាការមានភាពចាំបាច់ក្នុងការលើកឡើងអំពីការបកស្រាយច្បាប់ តុលាការត្រូវបង្ហាញអំពីការយល់ឃើញដែលនាំឲ្យមានការបកស្រាយច្បាប់ និង មូលហេតុនោះ ។

# សំអាងហេតុ

- ក្នុងករណីដែលតុលាការមានភាពចាំបាច់ក្នុងការលើកឡើងអំពីការបកស្រាយច្បាប់ តុលាការត្រូវបង្ហាញអំពីការយល់ឃើញដែលនាំឲ្យមានការបកស្រាយច្បាប់ និង មូលហេតុនោះ ។

- ដោយសារតែ មាត្រាដែលតុលាការបានយកមកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យ និង ការពន្យល់បន្ថែមទៅលើការវិនិច្ឆ័យជាអាទិ៍ គឺជាផ្នែកមួយនៃការវិនិច្ឆ័យរបស់តុលាការ ហេតុនេះហើយត្រូវលើកយកមកសរសេរនៅក្នុងតួសេចក្ដីនៃលិខិតសាលក្រម។ នៅក្នុងលិខិតសាលក្រម ការប្រើប្រាស់ជាលក្ខណៈ Footnote គឺមិនត្រឹមត្រូវទេ។

# សំអាងហេតុ

កម្មវត្ថុនៃការទទួលស្គាល់ដោយផ្អែកតាមភស្តុតាងគឺ អង្គហេតុ។ មិនត្រូវសរសេរជាលក្ខណៈនៃការទទួលស្គាល់នូវសិទ្ធិ និង កាតព្វកិច្ចភ្លាមៗ ដោយផ្អែកតាមភស្តុតាងនោះបានទេ។

ឧទា 1៖

× ផ្អែកតាមចម្លើយជាកសិណសាក្សីរបស់សាក្សី A តុលាការទទួលស្គាល់ថា ចុងចម្លើយទទួលបន្ទុកកាតព្វកិច្ចចំនួន……ដុល្លារ ។

○ ផ្អែកតាមចម្លើយជាកសិណសាក្សីរបស់សាក្សី A តុលាការទទួលស្គាល់ថា ដើមចោទបានប្រគល់ប្រាក់ចំនួន………ដុល្លារឲ្យទៅចុងចម្លើយផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់នៃរឿងក្តីនេះ។ ដូច្នេះហើយ តុលាការទទួលស្គាល់ថា ចុងចម្លើយទទួលបន្ទុកកាតព្វកិច្ចចំនួន …….ដុល្លារ ចំពោះដើមចោទ។

# សំអាងហេតុ

កម្មវត្ថុនៃការទទួលស្គាល់ដោយផ្អែកតាមភស្តុតាងគឺ អង្គហេតុ។ មិនត្រូវសេរសេរដាលក្ខណៈនៃការទទួលស្គាល់នូវសិទ្ធិ និង កាតព្វកិច្ចភ្លាមៗ ដោយផ្អែកតាមភស្តុតាងនោះបានទេ។

ឧទា 2៖

× ពុំមានភស្តុតាងដែលអាចបញ្ជាក់អំពីការរំលោយកិច្ចសន្យានៃរឿងក្តីនេះទេ។

○ ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីទទួលស្គាល់ថា ដើមចោទបានបង្ហាញឆន្ទៈអំពីការរំលោយកិច្ចសន្យានៃរឿងក្តីនេះទៅកាន់ចុងចម្លើយទេ។ ហេតុនេះ តុលាការមិនអាចទទួលស្គាល់អំពីការរំលោយកិច្ចសន្យានៃរឿងក្តីនេះទេ។

# សំអាងហេតុ

ចំពោះការទទួលស្គាល់អង្គហេតុ គឺគ្រាន់តែសរសេរអំពីអង្គហេតុដែលភាគីណាមួយមានបន្ទុកត្រូវបញ្ជាក់ភស្តុតាង ហើយបង្ហាញថា តុលាការទទួលស្គាល់អង្គហេតុនោះតាមរយៈភស្តុតាង ឬក៏ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីទទួលស្គាល់ទេ  ម្យ៉ាងទៀត ពុំចាំបាច់សរសេរថា គ្មានអង្គហេតុ ឬអាចទទួលស្គាល់អំពីអត្ថិភាពនៃអង្គហេតុផ្ទុយនោះទេ។

ឧទា៖

× តុលាការទទួលស្គាល់ថា ចុងចម្លើយមិនទាន់បានបង់ប្រាក់ថ្លៃលក់ទិញឲ្យទៅដើមចោទទេ។

○ ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីទទួលស្គាល់អង្គហេតុដែលលើកឡើងថា ចុងចម្លើយបានបង់ប្រាក់ថ្លៃលក់ទិញឲ្យទៅដើមចោទទេ។

# សំអាងហេតុ
# ឧទាហរណ៍នៃរបៀបសរសេរសំអាងហេតុ

- ករណីដែលអាចទទួលស្គាល់អង្គហេតុ(មានភស្តុតាងផ្ទាល់) ករណីដែលមានវិវាទអំពីការបង្កើត ឬ មិនបានបង្កើតនូវលិខិតកិច្ចសន្យាលក់ទិញ នៅក្នុងរឿងក្តីដែលមានលិខិតកិច្ចសន្យាជាអាទិ៍

"ផ្អែកតាមភស្តុតាងX1 តុលាការទទួលស្គាល់ថា កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះត្រូវបានបង្កើតឡើង។"

# សំអាងហេតុ
# ឧទាហរណ៍នៃរបៀបសរសេរសំអាងហេតុ

- ករណីដែលអាចទទួលស្គាល់អង្គហេតុ (គ្មានភស្តុតាងផ្ទាល់)

ត្រូវបញ្ជាក់ឲ្យបានច្បាស់ថា តើបានទទួលស្គាល់អង្គហេតុផ្ទាល់បែបណាដោយផ្អែកលើភស្តុតាងបែបណា?

"ផ្អែកតាមភស្តុតាង (សង្ខេប) តុលាការទទួលស្គាល់ថា ចុងចម្លើយបានជួបបញ្ហានឹងប្រាក់ដើមទុនសម្រាប់ការធ្វើអាជីវកម្មនៅអំឡុងខែកញ្ញា ឆ្នាំ2014 ហើយបានស្នើសុំកម្ចីឥណទានពី B បន្ទាប់មក B បានបដិសេធនឹងសំណើនោះ ហើយបានផ្តល់យោបល់ឲ្យចុងចម្លើយលក់ដីនៃរឿងក្តីនេះដែលជាកម្មសិទ្ធិរបស់ចុងចម្លើយដើម្បីយកប្រាក់នោះទៅបំពេញប្រាក់ដើមទុនសម្រាប់ការធ្វើអាជីវកម្ម ហើយនៅអំឡុងពេលនោះ C បានទទួលការពឹងពាក់ពីចុងចម្លើយថា ចង់ឲ្យរកអ្នកទិញដីនៃរឿងក្តីនេះ បន្ទាប់មកក៏បានណែនាំ Aដែលកំពុងតែស្វែងរកដីសម្រាប់ការធ្វើអាជីវកម្មទៅកាន់ចុងចម្លើយ..........................។

ប្រសិនបើសរុបអង្គហេតុទាំងនេះ តុលាការអាចសន្និដ្ឋានបានថា កិច្ចសន្យាលក់ទិញដីនៃរឿងក្តីនេះត្រូវបានបង្កើតឡើងរវាង A និងចុងចម្លើយ។"

# សំអាងហេតុ
# ឧទាហរណ៍នៃរបៀបសរសេរសំអាងហេតុ

- ករណីដែលអាចទទួលស្គាល់អង្គហេតុ

ក្នុងករណីដែលភាគីម្ខាងទៀតលើកឡើងនូវអង្គហេតុផ្សេងយកមកតវ៉ា ( ឧទារហរណ៍៖ ប្រសិនបើភាគីម្ខាងទៀតបានអះអាងថា ត្បូងមិនមែនជារបស់ដែលខ្លួនបានទិញនោះទេ ប៉ុន្តែ វាជារបស់ដែលបានពីគេ ) ដូច្នេះត្រូវបកស្រាយអំពីការអះអាងរបស់ភាគីម្ខាងទៀត។

“ចុងចម្លើយអះអាងថា ត្បូងនៃរឿងក្តីនេះមិនមែនជារបស់ដែលបានទិញទេ តែជារបស់ដែលបានពីគេ ប៉ុន្តែតុលាការមិនអាចទទួលយកការអះអាងនោះទេ ដោយសារតែ……”

# សំអាងហេតុ
# ឧទាហរណ៍នៃរបៀបសរសេរសំអាងហេតុ

- ករណីដែលមិនអាចទទួលស្គាល់អង្គហេតុ

"ផ្អែកតាមភស្តុតាង (សង្ខេប) តុលាការទទួលស្គាល់អង្គហេតុ.........។ ប៉ុន្តែ ទោះបីជាសរុបជារួមនូវអង្គហេតុដែលគ្មានវិវាទ និង អង្គហេតុដែលបានទទួលស្គាល់ខាងលើនេះក៏ដោយ ក៏តុលាការមិនអាចសន្និដ្ឋានបានថា អង្គហេតុ........ ហើយក្រៅពីនេះ ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីទទួលស្គាល់នូវអង្គហេតុ.......។"

# សំអាងហេតុ
# ឧទាហរណ៍នៃរបៀបសរសេរសំអាងហេតុ

- ករណីដែលមិនអាចទទួលស្គាល់អង្គហេតុ

ករណីដែលតុលាការទទួលស្គាល់នូវអង្គហេតុប្រយោលផ្សេងទៀតដោយមិនប្រើការសន្និដ្ឋាននូវអង្គហេតុច្បងផ្អែកតាមអង្គហេតុប្រយោលណាមួយ។

"ផ្អែកតាមភស្តុតាង A តុលាការទទួលស្គាល់អំពីអង្គហេតុa។
ក្រៅពីនេះ ផ្អែកតាមភស្តុតាង B តុលាការទទួលស្គាល់អំពីអង្គហេតុ b។
ប្រសិនបើធ្វើការពិចារណាដោយផ្អែកតាមអង្គហេតុ b តុលាការមិនអាចសន្និដ្ឋានអំពី អង្គហេតុ c ដែលដើមចោទអះអាងផ្អែកតាមអង្គហេតុ a ទេ ហើយក្រៅពីនេះ ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីទទួលស្គាល់នូវអង្គហេតុ c ទេ។"

# សំអាងហេតុ
# ឧទាហរណ៍នៃរបៀបសរសេរសំអាងហេតុ

- អំពីការជឿជាក់លើសាក្សី

នៅពេលដែលធ្វើការសាកសួរសាក្សី ឬ សាកសួរសាមីភាគី ភាគច្រើនសាក្សីខាងភាគីដើមចោទ និង សាក្សីខាងភាគីចុងចម្លើយធ្វើសេចក្តីសំអាងដែលមានលក្ខណៈផ្ទុយគ្នា ហេតុនេះហើយ តុលាការមិនអាចជឿជាក់គ្រប់សាក្សីបាននោះទេ។ ក្នុងករណីដែលមិនអាចជឿជាក់លើសេចក្តីសំអាងរបស់សាក្សីណាមួយ  តុលាការត្រូវសរសេរអំពីមូលហេតុនោះ។

"សេចក្តីសំអាងរបស់សាក្សី A មានចំណុចដែលមិនច្បាស់លាស់ និង ចំណុចផ្ទុយគ្នាច្រើន ហេតុនេះ តុលាការមិនអាចជឿជាក់បានទេ។"

"សេចក្តីសំអាងរបស់សាក្សី B ផ្ទុយនឹងការសរសេរអំពីភស្តុតាងX1 ហេតុនេះហើយតុលាការមិនអាចជឿជាក់បានទេ។"

# សំអាងហេតុ

## សំអាងហេតុអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី និង ការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន

បន្ទុកនៃប្រាក់ប្រដាប់ក្តីគឺជាឆន្ទានុសិទ្ធិរបស់តុលាការក្នុងការសម្រេច (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 65) រីឯការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នវិញ ក៏ជាឆន្ទានុសិទ្ធិរបស់តុលាការក្នុងការប្រកាសផងដែរ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 196 កថាខណ្ឌទី 1) ហេតុនេះ គេគិតថា ប្រសិនបើតុលាការសរសេរអំពីមូលហេតុទាំងនោះ គឺអាចសរសេរត្រួសៗក៏បាន។

ឧទាហរណ៍អំពីការសរសេរ៖ ចំពោះប្រាក់ប្រដាប់ក្តីគួរតែសរសេរថា ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី បង្គាប់ឲ្យដើមចោទទទួលបន្ទុក .......% ហើយចុងចម្លើយទទួលបន្ទុក.......%។ ចំពោះការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន គួរតែសរសេរថា ប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ននូវចំណុចទី......និង ចំណុចទី......នៃសេចក្តីសម្រេចបញ្ចប់។

# ចំណុចដែលត្រូវសរសេរក្នុងលិខិតសាលក្រម

1. សញ្ញាណនៃរឿងក្តី
2. ចំណងជើង
3. តុលាការ( ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា189 កថាខណ្ឌទី1 ចំណុច ក )
4. ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 189 កថាខណ្ឌទី1 ចំណុច ខ )
5. អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច គ )
6. អង្គហេតុ និង ចំណុចវិវាទ ( ក្រមនីតិវិធីរដ្ឋប្បវេណី189 កថាខណ្ឌទី1 ចំណុច ឃ )
7. សំអាងហេតុ ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី ចំណុច ង )
8. **សេចក្តីសម្រេចបញ្ចប់ ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច ច )**
9. ហត្ថលេខាចៅក្រម ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី3 )

# សេចក្តីសម្រេចបញ្ចប់

- សេចក្តីសម្រេចបញ្ចប់អំពីការលើកចោលពាក្យបណ្តឹង (ករណីដែលខ្វះលក្ខខណ្ឌនៃពាក្យបណ្តឹង)

"លើកចោលពាក្យបណ្តឹងនៃរឿងក្តីនេះ"

- សេចក្តីសម្រេចបញ្ចប់អំពីការច្រានចោលការទាមទារ (ករណីដែលការទាមទាររបស់ដើមចោទគ្មានមូលហេតុ)

  "ច្រានចោលការទាមទាររបស់ដើមចោទ"

✓ក្នុងករណីដែលតុលាការទទួលស្គាល់ការទាមទារមួយផ្នែករបស់ដើមចោទ ត្រូវតែបង្ហាញឲ្យបានច្បាស់នៅក្នុងសេចក្តីសម្រេចបញ្ចប់ថា " ច្រានចោលការទាមទារផ្សេងពីនេះរបស់ដើមចោទ" ។

# សេចក្តីសម្រេចបញ្ចប់

- សេចក្តីសម្រេចបញ្ចប់អំពីការទទួលស្គាល់នូវការទាមទារ

  សេចក្តីសម្រេចបញ្ចប់អំពីការទទួលស្គាល់នូវការទាមទាររបស់ដើមចោទ ជាធម្មតា គឺជាការឆ្លើយតបទៅនឹង "ខ្លឹមសារនៃសាលក្រមដែលទាមទារ" ដែលបានសរសេរនៅក្នុងពាក្យបណ្តឹង។ ប៉ុន្តែ នៅពេលដែលការសរសេរនៅក្នុងពាក្យបណ្តឹងមានលក្ខណៈខុសប្លែក តុលាការត្រូវបង្គាប់ឲ្យដើមចោទផ្លាស់ប្តូរពាក្យបណ្តឹង (ផ្លាស់ប្តូរនូវខ្លឹមសារនៃសាលក្រមដែលទាមទារ) ដោយផ្អែកតាមភាពត្រឹមត្រូវនៃការបំភ្លឺ។

# សេចក្តីសម្រេចបញ្ចប់
# សេចក្តីសម្រេចបញ្ចប់នៃសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិក

ត្រូវសរសេរនូវខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់ឲ្យមានលក្ខណៈច្បាស់លាស់ទោះបីជាមើលមួយភ្លែតក៏ដោយ។ នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិក មិនត្រូវប្រើប្រាស់ពាក្យពេចន៍អរូបីដែលលើកឡើងនូវលក្ខណៈតាវកាលិកផ្អែកតាមផ្លូវច្បាប់ ឬ ដោយការភ្ជាប់ជាមួយមូលហេតុទេ។

ឧទាហរណ៍នៃការសរសេរ:

× "បង្គាប់ឲ្យបង់ប្រាក់កម្ចីចំនួន..........ដុល្លារ។ "

○ "បង្គាប់ឲ្យបង់ប្រាក់ចំនួន...........ដុល្លារ"។

× "បង្គាប់ឲ្យប្រគល់ដី............ដែលជាកម្មសិទ្ធិរបស់ចុងចម្លើយ។"

○ "បង្គាប់ឲ្យប្រគល់ដី..........។"

# សេចក្តីសម្រេចបញ្ចប់
## សេចក្តីសម្រេចបញ្ចប់នៃសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិក

សាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិក គឺជាសាលក្រមដែលតុលាការបង្គាប់ឲ្យភាគីអនុវត្តកាតព្វកិច្ច ដូច្នេះហើយ សេចក្តីសម្រេចបញ្ចប់ត្រូវសរសេរដោយប្រើទម្រង់បង្គាប់បញ្ជា។ ត្រូវជៀសវាងនូវការប្រើទម្រង់ដែលធ្វើឲ្យច្រឡំជាមួយនឹងសាលក្រមបញ្ជាក់។

- × "ចុងចម្លើយត្រូវតែបង់ប្រាក់ចំនួន........ដុល្លារឲ្យទៅដើមចោទ។ "
- × "បញ្ជាក់ថា ចុងចម្លើយត្រូវបង់ប្រាក់ឲ្យទៅដើមចោទចំនួន........ដុល្លារ។"

# សេចក្តីសម្រេចបញ្ចប់
## សេចក្តីសម្រេចបញ្ចប់នៃសាលក្រមដែលបង្គាប់ឲ្យផ្តល់សាច់ការលិក

សេចក្តីសម្រេចបញ្ចប់ដែលបង្គាប់ឲ្យបង់ប្រាក់

"បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន......... និង ប្រាក់ចំនួន 5%ក្នុង1ឆ្នាំនៃប្រាក់នេះ គិតចាប់ពីថ្ងៃទី.....ខែ.....ឆ្នាំ...........រហូតដល់ថ្ងៃបង់រួច។

- ទោះបីជានៅក្នុងខ្លឹមសារនៃសាលក្រមដែលទាមទារក្នុងពាក្យបណ្តឹងបានសរសេរថា " គិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃបញ្ជូនពាក្យបណ្តឹង" ក៏ដោយ នៅពេលដែលសរសេរសាលក្រម គប្បីសរសេរអំពីថ្ងៃឲ្យបានជាក់លាក់ ដោយសារតែ "ថ្ងៃបន្ទាប់នៃថ្ងៃបញ្ជូនពាក្យបណ្តឹង" ត្រូវបកស្រាយឲ្យបានច្បាស់លាស់។

# សេចក្តីសម្រេចបញ្ចប់

## សេចក្តីសម្រេចបញ្ចប់នៃសាលក្រមដែលបង្គាប់ឲ្យផ្តល់គាលិក

សេចក្តីសម្រេចបញ្ចប់ដែលបង្គាប់ឲ្យបង់ប្រាក់

"បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន.......... និង ប្រាក់ផ្អែកតាមការប្រាក់ចំនួន 5%ក្នុងមួយឆ្នាំនៃប្រាក់នេះគិតចាប់ពីថ្ងៃទី.....ខែ.....ឆ្នាំ...........រហូតដល់ថ្ងៃបង់រួច។

- ក្នុងករណីដែលជាការទាមទារឲ្យកូនបំណុលច្រើនបង់កាតព្វកិច្ចសាមគ្គី ប្រសិនបើគ្រាន់តែសរសេរថា "បង្គាប់ឲ្យសហចុងចម្លើយបង់ប្រាក់ចំនួន..........ដុល្លារឲ្យទៅដើមចោទ" នោះ នឹងធ្វើឲ្យមិនដឹងថា តើកាតព្វកិច្ចនេះ គឺជាកាតព្វកិច្ចដែលអាចបែងចែកបាន ឬក៏ ជាកាតព្វកិច្ចសាមគ្គីនោះទេ ដូច្នេះ ជាឧទាហរណ៍គប្បីសរសេរថា " បង្គាប់ឲ្យសហចុងចម្លើយនីមួយៗបង់ប្រាក់ចំនួន...........ឲ្យទៅដើមចោទ។"

# សេចក្តីសម្រេចបញ្ចប់
# សេចក្តីសម្រេចបញ្ចប់នៃសាលក្រមដែលបង្គាប់ឲ្យផ្តល់ឆន្ទការលិក

សេចក្តីសម្រេចបញ្ចប់ដែលបង្គាប់ឲ្យធ្វើនីតិវិធីចុះបញ្ជី

"បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដីដែលបានកត់ត្រាក្នុងតារាងឧបសម្ព័ន្ធស្តីពីវត្ថុដោយមូលហេតុនៃការលក់ទិញចុះថ្ងៃទី......ខែ.......ឆ្នាំ......។"

- នេះគឺជាសេចក្តីសម្រេចបញ្ចប់ដែលបង្គាប់នូវការបង្ហាញឆន្ទៈ ដូច្នេះប្រសិនបើសាលក្រមនេះបានចូលជាស្ថាពរនឹងត្រូវចាត់ទុកថា ចុងចម្លើយបានបង្ហាញឆន្ទៈអំពីការចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា529 កថាខណ្ឌទី1)។ ហើយ ដើមចោទអាចធ្វើនីតិវិធីចុះបញ្ជីតែម្នាក់ឯងបាន (ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអំពីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី ប្រការ10 កថាខណ្ឌទី 2)។
- ដើម្បីឲ្យមន្ត្រីចុះបញ្ជីអាចចុះបញ្ជីបានត្រឹមត្រូវដោយគ្រាន់តែមើលលើសេចក្តីសម្រេចបញ្ចប់នៃសាលក្រមហេតុនេះត្រូវតែកំណត់ឲ្យបានច្បាស់លាស់អំពីកម្មវត្ថុនៃការចុះបញ្ជី និង ខ្លឹមសារនៃការចុះបញ្ជី។

# សេចក្តីសម្រេចបញ្ជាប់
## សេចក្តីសម្រេចបញ្ជាប់នៃសាលក្រមដែលបង្គាប់ឲ្យផ្តល់ឆាវភាលិក

សេចក្តីសម្រេចបញ្ជាប់ដែលបង្គាប់ឲ្យធ្វើនីតិវិធីចុះបញ្ជី

"បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដីដែលបានកត់ត្រាក្នុងតារាងឧបសម្ព័ន្ធស្តីពីវត្ថុ ដោយមូលហេតុនៃការលក់ទិញចុះថ្ងៃទី......ខែ......ឆ្នាំ......។"

× "..........មន្ត្រីចុះបញ្ជី (សុរិយោដី មន្ទីរដែនដី )......ឲ្យទៅដើមចោទ។"
មន្ត្រីចុះបញ្ជីជាអាទិ៍មិនមែនត្រូវទទួលបន្ទុកកាតព្វកិច្ចណាមួយចំពោះដើមចោទទេ។ ការដែលបង្គាប់អ្វីមួយទៅកាន់មន្ត្រីចុះបញ្ជីជាអាទិ៍ដែលមិនមែនជាភាគីនៃសេចក្តីសម្រេច គឺជាការមិនត្រឹមត្រូវទេ។

# សេចក្ដីសម្រេចបញ្ចប់

## សេចក្ដីសម្រេចបញ្ចប់នៃសាលក្រមបញ្ជាក់

សាលក្រមបញ្ជាក់ គឺជាសាលក្រមដែលបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងសិទ្ធិដែលជាកម្មវត្ថុនៃបណ្ដឹង ដូច្នេះហើយត្រូវសរសេរថា " បញ្ជាក់ថា .......” ។ គប្បីជៀសវាងនូវការប្រើប្រាស់ពាក្យពេចន៍ដែលធ្វើឲ្យច្រឡំជាមួយនឹងសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិក។

× "បង្គាប់ឲ្យចុងចម្លើយបញ្ជាក់ថា ..........ចំពោះដើមចោទ។”

× "ចុងចម្លើយត្រូវតែបញ្ជាក់ថា ...............។”

# សេចក្តីសម្រេចបញ្ចប់

## សេចក្តីសម្រេចបញ្ចប់នៃសាលក្រមបញ្ជាក់

ឧទាហរណ៍លម្អិតស្តីពីសេចក្តីសម្រេចបញ្ចប់នៃសាលក្រមបញ្ជាក់

ឧទា1៖ បញ្ជាក់ថា ដើមចោទមានកម្មសិទ្ធិលើដីដែលបានកត់ត្រាក្នុងតារាងឧបសម្ព័ន្ធស្តីពីវត្ថុ។

ឧទា2៖ បញ្ជាក់ថា ដើមចោទមិនមានកាតព្វកិច្ចសងប្រាក់ដើមចំនួន......ដុល្លារឲ្យទៅចុងចម្លើយដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី.....ខែ......ឆ្នាំ......រវាងដើមចោទ និង ចុងចម្លើយទេ។

# សេចក្តីសម្រេចបញ្ជាប់

## សេចក្តីសម្រេចបញ្ជាប់នៃសាលក្រមបង្កើត ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

សាលក្រមបង្កើត ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាសាលក្រមដែលមានគោលបំណងបង្កើតដោយផ្ទាល់ ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តផ្អែកតាមរយៈសាលក្រមនោះ ដូច្នេះហើយត្រូវបង្ហាញឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងសិទ្ធិដែលត្រូវបានបង្កើតឡើងតាមរយៈសេចក្តីសម្រេចបញ្ចប់។ គប្បីជៀសវាងការប្រើប្រាស់ពាក្យពេចន៍ដែលធ្វើឲ្យច្រឡំនឹងសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិក ឬ សាលក្រមបញ្ជាក់។

ឧទាហរណ៍លម្អិត 1 (សេចក្តីសម្រេចបញ្ចប់អំពីការលែងលះ)

○ "លែងលះដើមចោទ និង ចុងចម្លើយ។"

× "បង្គាប់ឲ្យដើមចោទលែងលះចុងចម្លើយ។"

# សេចក្តីសម្រេចបញ្ចប់

# សេចក្តីសម្រេចបញ្ចប់នៃសាលក្រមបង្កើត ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

សាលក្រមបង្កើត ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាសាលក្រមដែលមានគោលបំណងបង្កើតដោយផ្ទាល់ ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តផ្អែកតាមរយៈសាលក្រមនោះ ដូច្នេះហើយត្រូវបង្ហាញឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងសិទ្ធិដែលត្រូវបានបង្កើតឡើងតាមរយៈសេចក្តីសម្រេចបញ្ចប់។ គប្បីជៀសវាងការប្រើប្រាស់ពាក្យពេចន៍ដែលធ្វើឲ្យច្រឡំនឹងសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិក ឬ សាលក្រមបញ្ជាក់។

ឧទាហរណ៍លម្អិត 2 (សេចក្តីសម្រេចបញ្ចប់អំពីការតវ៉ាចំពោះការទាមទារ)

○ "មិនអនុញ្ញាតឲ្យអនុវត្តដោយបង្ខំពីចុងចម្លើយទៅកាន់ដើមចោទផ្អែកតាមសាលក្រមនៃរឿងក្តី (ឈ្មោះតុលាការ លេខសំណុំរឿង ឈ្មោះសំណុំរឿង)ទេ។"

× "ចុងចម្លើយមិនត្រូវអនុវត្តដោយបង្ខំចំពោះដើមចោទផ្អែកតាមសាលក្រមនៃរឿងក្តី (ឈ្មោះតុលាការ លេខសំណុំរឿង ឈ្មោះសំណុំរឿង)ទេ។"

# សេចក្តីសម្រេចបញ្ចប់
# ការប្រើប្រាស់តារាងឧបសម្ព័ន្ធ

ប្រសិនបើសរសេរអំពីពត៌មានដែលចាំបាច់សម្រាប់កំណត់អំពីកម្មវត្ថុ ឬ ការចុះបញ្ជីជាអាទិ៍ ទាំងស្រុងចូលក្នុងសេចក្តីសម្រេចបញ្ចប់ នឹងអាចធ្វើឲ្យសេចក្តីសម្រេចបញ្ចប់វែងជ្រុល។ ក្នុងករណីបែបនេះ គេបានលើកឡើងនូវវិធីមួយដោយធ្វើការភ្ជាប់នូវតារាងស្តីពីវត្ថុ ឬ រូបភាពធ្វើជាឧបសម្ព័ន្ធ ហើយចំណុចដែលទាក់ទងនឹងការសរសេរសេចក្តីសម្រេចបញ្ចប់នឹងត្រូវលើកឡើងនៅក្នុងឧបសម្ព័ន្ធនេះ ហើយបង្ហាញអំពីកម្មវត្ថុជាអាទិ៍។

ឧទា ៖  បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីលុបចោលហ៊ីប៉ូតែកដែលបានកត់ត្រានៅក្នុងតារាងឧបសម្ព័ន្ធស្តីពីការចុះបញ្ជីលើដីដែលបានកត់ត្រានៅក្នុងតារាងឧបសម្ព័ន្ធស្តីពីវត្ថុ ដោយមូលហេតុនៃការសងចុះថ្ងៃទី......ខែ.....ឆ្នាំ.........។

# សេចក្តីសម្រេចបញ្ចប់
## សេចក្តីសម្រេចបញ្ចប់អំពីប្រាក់ប្រដាប់ក្តី

ចំពោះប្រាក់ប្រដាប់ក្តី តុលាការត្រូវតែសម្រេចដោយឆន្ទានុសិទ្ធិ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 65) ហេតុនេះ គប្បីសរសេរនៅក្នុងសេចក្តីសម្រេចបញ្ចប់។ ប្រាក់ប្រដាប់ក្តី គឺជាប្រាក់ដែលកើតឡើងនៅក្រោយពេលនៃការប្រកាសសាលក្រម (រួមមានសោហ៊ុយនៃការបញ្ជូនសាលក្រមជាអាទិ៍) ហើយមិនមែនជាការងាយស្រួលក្នុងការគណនាចំនួនទឹកប្រាក់ជាក់ស្តែងនោះឲ្យបានត្រឹមត្រូវទេ ហេតុនេះហើយ នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រមគ្រាន់តែកំណត់អំពីអ្នកដែលត្រូវទទួលបន្ទុកសិនក៏បាន។ កន្លែងដែលត្រូវសរសេរនៅក្នុងសេចក្តីសម្រេចបញ្ចប់ គឺត្រូវសរសេរនៅក្រោយសេចក្តីសម្រេចអំពីការទាមទារ ហើយមុនការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន។

ឧទាហរណ៍នៃការសរសេរ 1 ៖ ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ចុងចម្លើយ។
ឧទាហរណ៍នៃការសរសេរ 2 ៖ កំណត់ប្រាក់ប្រដាប់ក្តីជា 5 ចំណែក ដោយដើមចោទត្រូវទទួលបន្ទុក 2 ចំណែក ហើយក្រៅពីនេះជាបន្ទុករបស់ចុងចម្លើយ។

# សេចក្តីសម្រេចបញ្ចប់
## សេចក្តីសម្រេចបញ្ចប់អំពីប្រាក់ប្រដាប់ក្តី

ចំពោះប្រាក់ប្រដាប់ក្តី តុលាការត្រូវតែសម្រេចដោយឆន្ទានុសិទ្ធិ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 65) ហេតុនេះ គប្បីសរសេរនៅក្នុងសេចក្តីសម្រេចបញ្ចប់។ ប្រាក់ប្រដាប់ក្តី គឺជាប្រាក់ដែលកើតឡើងនៅក្រោយពេលនៃការប្រកាសសាលក្រម (រួមមានសោហ៊ុយនៃការបញ្ជូនសាលក្រមជាអាទិ៍) ហើយមិនមែនជាការងាយស្រួលក្នុងការគណនាចំនួនទឹកប្រាក់ជាក់ស្តែងនោះឲ្យបានត្រឹមត្រូវទេ ហេតុនេះហើយ នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រមគ្រាន់តែកំណត់អំពីអ្នកដែលត្រូវទទួលបន្ទុកសិនក៏បាន។ កន្លែងដែលត្រូវសរសេរនៅក្នុងសេចក្តីសម្រេចបញ្ចប់ គឺត្រូវសរសេរនៅក្រោយសេចក្តីសម្រេចអំពីការទាមទារ ហើយមុនការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន។

ឧទាហរណ៍នៃការសរសេរ 3 ៖ ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់សហាចុងចម្លើយ។

✓ ប្រសិនបើសរសេរបែបនេះ ពេលនោះសហចុងចម្លើយនឹងត្រូវទទួលបន្ទុកដោយស្មើភាពគ្នាផ្អែកតាមផ្លូវច្បាប់ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា64 កថាខណ្ឌទី3)។

# សេចក្តីសម្រេចបញ្ចប់
## សេចក្តីសម្រេចបញ្ចប់អំពីការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន

- នៅពេលដែលប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នចាំបាច់ត្រូវតែយកមកសរសេរនៅក្នុងសេចក្តីសម្រេចបញ្ចប់ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៩៦ កថាខណ្ឌទី3)។ ការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នត្រូវយកមកសរសេរបន្ទាប់ពីសេចក្តីសម្រេចអំពីប្រាក់ប្រដាប់ក្តី។

- មិនអាចធ្វើការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នចំពោះសាលក្រមបញ្ជាក់ សាលក្រមបង្កើតផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត និង សាលក្រមដែលបង្គាប់ឲ្យបង្ហាញឆន្ទៈបានទេ។

- អាចធ្វើការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នចំពោះសេចក្តីសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តីបាន។

# សេចក្តីសម្រេចបញ្ចប់
## សេចក្តីសម្រេចបញ្ចប់អំពីការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន

ឧទាហរណ៍នៃការសរសេរលម្អិត៖

ឧទា 1 ៖ សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន។

✓ប្រសិនបើសរសេរបែបនេះ មានន័យថា តុលាការបានប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នចំពោះសេចក្តីសម្រេចបញ្ចប់ទាំងស្រុង (រួមទាំងសេចក្តីសម្រេចអំពីប្រាក់ប្រដាប់ក្តីផងដែរ)។

ឧទា 2 ៖ សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានតែចំណុចទី.....។

# ចំណុចដែលត្រូវសរសេរក្នុងលិខិតសាលក្រម

1. សញ្ញាណនៃរឿងក្ដី
2. ចំណងជើង
3. តុលាការ(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា189 កថាខណ្ឌទី1 ចំណុច ក)
4. ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់(ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 189 កថាខណ្ឌទី1 ចំណុច ខ)
5. អត្តសញ្ញាណភាគី និង អ្នកតំណាង ជាអាទិ៍(ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច គ)
6. អង្គហេតុ និង ចំណុចវិវាទ (ក្រមនីតិវិធីរដ្ឋប្បវេណី189 កថាខណ្ឌទី1 ចំណុច ឃ)
7. សំអាងហេតុ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី ចំណុច ង)
8. សេចក្ដីសម្រេចបញ្ចប់ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី1 ចំណុច ច)
9. **ហត្ថលេខាចៅក្រម (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា189 កថាខណ្ឌទី3)**

# ហត្ថលេខាចៅក្រម

- ចៅក្រមដែលចេញសាលក្រមត្រូវចុះហត្ថលេខាលើលិខិតសាលក្រម (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 189 កថាខណ្ឌទី3)។ "ចៅក្រមដែលចេញសាលក្រម" ត្រង់ចំណុចនេះ គឺជាចៅក្រមដែលបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ចុងក្រោយ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 185 កថាខណ្ឌទី 1) ហើយមិនមែនជាចៅក្រមដែលធ្វើការប្រកាសសាលក្រមទេ។

- ក្នុងករណីដែលចៅក្រមណាម្នាក់ក្នុងចំណោមក្រុមប្រឹក្សាជំនុំជម្រះ មានធុរៈក្នុងការចុះហត្ថលេខាលើលិខិតសាលក្រម ចៅក្រមផ្សេងទៀតត្រូវចុះហត្ថលេខា ដោយចុះនិទ្ទេសអំពីហេតុដែលចៅក្រមនោះមិនអាចចុះហត្ថលេខាបាន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 189កថាខណ្ឌទី4)។

# Thank you for listening !